**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារ

## របស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

*ជនរួមជាតិជាទីស្នេហា!*

នៅក្នុងពេលបច្ចុប្បន្នប្រទេសកម្ពុជាយើងកំពុងតែជួបប្រទះនឹងគ្រោះភ័យ ដែលបង្កឡើងដោយជំងឺរីករាលដាលកូវីដ-១៩ (COVID-19) ដែលរាជរដ្ឋាភិបាលកំពុងតែចាត់វិធានការមួយចំនួនដើម្បីទប់ទល់ជំងឺដ៏កាចសាហាវមួយនេះ ។

**ព្រះករុណាព្រះមហាក្សត្រ** ទីជាសក្ការៈនៃយើង និង**សម្តេចព្រះវររាជមាតាជាតិខ្មែរ** ដែលទ្រង់តែងតែយកព្រះរាជហឫទ័យទុកដាក់ចំពោះសុខទុក្ខរបស់ប្រជាជនជាកូនចៅ ចៅទួតរបស់ព្រះអង្គ ទ្រង់បានសព្វព្រះរាជហឫទ័យប្រោសព្រះរាជប្រទាន ដោយព្រះរាជទ្រព្យផ្ទាល់ជាថវិកាសរុបចំនួន **300.000 (បីរយពាន់) ដុល្លារអាមេរិក** ជាព្រះរាជគំរូដ៏ឧត្តុង្គឧត្តម សម្រាប់ជួយដល់រាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ចខាងលើ ។ ម្យ៉ាងទៀត ក៏មានសប្បុរសជនមួយចំនួនដែលបានផ្តល់ជាជំនួយជាថវិកាមួយចំនួនធំរួចមកហើយផងដែរ ។

រាជរដ្ឋាភិបាលសូមថ្លែងនូវអំណរគុណទុកជាមុន ចំពោះសប្បុរសជនទាំងឡាយណាដែលនឹងបន្តផ្តល់ជំនួយដល់រាជរដ្ឋាភិបាល ហើយដើម្បីជាកិច្ចសម្រួលដល់ការទទួលជំនួយទាំងឡាយនោះ រាជរដ្ឋាភិបាលបានកំណត់ទីតាំងចំនួន ០២កន្លែង សម្រាប់ទទួលស្វាគមន៍ជំនួយសប្បុរស៖

- កន្លែងទី១ គឺគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលមានរូបខ្ញុំជាប្រធាន ហើយអាស័យដ្ឋាននៅក្រសួងសុខាភិបាលនិងមានឈ្មោះមន្ត្រី និងលេខទូរស័ព្ទអ្នកចាំទទួល (តាមប្រកាសលេខ ០៤៦ សខល ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២០ របស់ក្រសួងសុខាភិបាល)
- កន្លែងទី២ គឺខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលមានឯកឧត្តម **សេង ទៀង** នាយករងខុទ្ទកាល័យ (012 961 971) និងមន្ត្រីមួយចំនួនទៀតជាអ្នករង់ចាំទទួល។

ដោយបានជំនួយដែលនឹងត្រូវបានផ្តល់ រាជរដ្ឋាភិបាលនឹងខិតខំធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីសង្គ្រោះនិងការពារជីវិតរបស់ប្រជាជនកម្ពុជានៃយើង។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់បងប្អូនជនរួមជាតិ សូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ហើយនឹងជៀសផុតអំពីជំងឺដ៏កាចសាហាវដែលកំពុងតែគំរាមកំហែងទូទាំងពិភពលោកនេះ។

*ថ្ងៃ សុក្រ ១២រោច ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២០

**ហ៊ុន សែន**